# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

*KINGDOM OF CAMBODIA*
*Nation - Religion - King*

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ៣១៤ សព.ណ....

ភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៦

## សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា សូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា កន្លងទៅថ្មីៗនេះ គណៈកម្មាធិការជាតិ បានទទួលសំណើសុំសិទ្ធិគ្រប់គ្រងមរតកសាសន៍បទចំរៀង ពីលោក ស៊ីន ច័ន្ទឆាយា ដែលជាកូនបង្កើតតារាចំរៀងឯក លោក ស៊ីន ស៊ីសាមុត ហើយបានពិភាក្សាសំណើនេះ ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ជាលទ្ធផល យើងបានរកឃើញថា មានបទចំរៀងចំនួន ៧៣ បទ (ដូចបានជូនភ្ជាប់) ដែលជាស្នាដៃនិពន្ធទំនុកច្រៀងនិង/ឬបទភ្លេង ដោយលោកស៊ីនស៊ីសាមុត។

អាស្រ័យដូចបានជម្រាបជូនខាងលើ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា សូមប្រកាសជូនដំណឹងថា រាល់ភាគីពាក់ព័ន្ធទាំងអស់ ដែលមានបំណងចង់ប្តឹងជំទាស់ប្រឆាំងនឹងការផ្ទេរសិទ្ធិមរតកសាសន៍លើបទចំរៀងខាងលើ អាចដាក់ពាក្យប្តឹងមកលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលមានអាសយដ្ឋានស្ថិតនៅឡូត៍លេខ១៩-៦១ ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ លេខ ០១២ ៨២ ៦១ ៦៦ និង ០១២ ៩៧ ៥៧ ៥៥។ រយៈពេលនៃការដាក់ពាក្យប្តឹងជំទាស់ គឺមានសុពលភាពរយៈពេល ០១ខែ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ។

គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា នឹងពិនិត្យបន្ថែមចំពោះសំណើសុំសិទ្ធិគ្រប់គ្រងមរតកសាសន៍លើបទចំរៀង របស់តារាចំរៀងឯកដទៃទៀត ក្នុងកំឡុងទស្សវត្ស ទី ៦០ ដូចជា អ្នកស្រី រស់ សេរីសុទ្ធា អ្នកស្រី ប៉ែន រ៉ន ជាដើម ប្រសិនបើមានសំណើពីសាច់ញាតិ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា**

ស៊ុន ចាន់ថុល

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- ឯកសារ-កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ,ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sankat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

# បញ្ជីបទចម្រៀង

| ល.រ | ចំណងជើងបទចម្រៀង | | | | |
|---|---|---|---|---|---|
| ១ | សូរិយាមាសបង | ២៦ | រឿងស្នេហ៍នៃយើង | ៥១ | ជ្រលងសេកមាស |
| ២ | ហ៊ានស្លាប់ព្រោះបង | ២៧ | សូមបងអាណិត | ៥២ | បុប្ផាកោះរុំដួល |
| ៣ | ព្រិលភ្នែកអស់ហើយ | ២៨ | គួរឱ្យរៀង | ៥៣ | បំពេរទិព្វសួដាច័ន្ទ |
| ៤ | ចុតហ្មាយមច្ចុរាជ | ២៩ | បើស្រឡាញ់អូនពិត | ៥៤ | អក្ខរាលោហិត |
| ៥ | ចិញ្ចៀនត្បូងប្រាំ | ៣០ | ថ្ងៃក្រោយជួបទៀត | ៥៥ | កំពីងពួយ |
| ៦ | ផ្គរលាន់ឯត្បូង | ៣១ | រស់រងកម្ម | ៥៦ | កុំនឹកគេអី |
| ៧ | ស្នេហាអង្គិសុវណ្ណច័ន្ទកេសរ | ៣២ | សមគ្មានទាស់ | ៥៧ | ស្វាយមួយមែក |
| ៨ | ជំនោរកត្តិក | ៣៣ | នួនល្អងព្រមទៅ | ៥៨ | ព្រៃឯកើត |
| ៩ | ថ្ងៃស្អែកបែកគ្នា | ៣៤ | ចង់បំភ្លេចដែរ | ៥៩ | ទឹកភ្នែកម៉ាឡាវី |
| ១០ | ផ្កាល្មៀត | ៣៥ | ស្មារតីរន្ធត់ | ៦០ | វាសនាខ្សែទឹកឈូ |
| ១១ | បេះបានឬទេ | ៣៦ | ពេលដែលត្រូវយំ | ៦១ | កាលអូនរាំMonkeys |
| ១២ | ប្រគល់ក្ដីស្នេហ៍មកខ្ញុំវិញ | ៣៧ | រឿងស្នេហ៍ខ្ញុំ | ៦២ | កុំតែចោលអូន |
| ១៣ | មើបទឹកភ្នែកអូនឱ្យស្ងួត | ៣៨ | មើលមេឃមើលស្រី | ៦៣ | ស្អែកអូនលាបងហើយ |
| ១៤ | កុំដាច់ចិត្តចោលបង | ៣៩ | បុប្ផាមហាអង្គរ | ៦៤ | ក្រមុំខ្មែរលើ |
| ១៥ | យល់ចិត្តរៀមផង | ៤០ | សម្ពាយកម្ម | ៦៥ | ផល្លី ផល្លី |
| ១៦ | ស្រីតូចច្រឡឹង | ៤១ | វង្វេងលើខ្នើយ | ៦៦ | ថាវរី |
| ១៧ | កាលណាអូនច្រៀង | ៤២ | នឹកគ្រប់វេលា | ៦៧ | ផ្កាក្រហម |
| ១៨ | ចម្រៀងមួយច្រៀងពីរនាក់ | ៤៣ | ធ្វើអីក៏ធ្វើដែរ | ៦៨ | កន្លង់ផ្ញើប្រាណ |
| ១៩ | ទឹកភ្នែកនៅពេលបែកគ្នា | ៤៤ | ទំនួញនាងកេសរបុទុំមា | ៦៩ | ព្រាត់ស្វាមី |
| ២០ | មើលព្រៃព្រឹក្សា | ៤៥ | ចំប៉ាវត្តិពិលាប | ៧០ | ស្នេហាពិន្ទវង្ស |
| ២១ | បើផ្ការីកថ្មី | ៤៦ | ស្រណោះសំដី | ៧១ | សម្លេងស្រែកហៅ |
| ២២ | រថភ្លើងអប្រាត្រឃ្លាតសង្សារ | ៤៧ | ស្រណោះភ្លៀងម្ដង | ៧២ | អក្ខរាផ្ញើទៅស្រី |
| ២៣ | ថ្ងៃនេះម្ដេចអូនធ្វើព្រងើយ | ៤៨ | ទឹកហូរក្រោមស្ពាន | ៧៣ | ថ្ងៃនេះមិនចូលផ្ទះទេ |
| ២៤ | ស្ពាយឆោម | ៤៩ | រឿងខ្ញុំ | | |
| ២៥ | មាន់ រងាវ | ៥០ | ថ្ងៃណាមេឃស្រឡះ | | |



